# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

## អនុក្រឹត្យលេខ ១៧ អនក្រ បក

## ស្តីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជ ក្រម ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ របស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

-ដើម្បីធានាតំលាភាពគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការអនុវត្តន៍គំរោងវិនិយោគសាធារណៈ

-យោងតាមតម្រូវការចាំបាច់

## សំរេច

**មាត្រា ១.-** បង្កើតប្រព័ន្ធជាតិមួយមានឈ្មោះថា : "ប្រព័ន្ធជាតិសំរាប់ការគ្រប់គ្រងវិនិយោគសាធារណៈ"សំរាប់គ្រប់គ្រងការងារវិនិយោគសាធារណៈ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងកំណត់តួនាទី និង មុខងាររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធស្តីពីការរៀបចំផែនការ និងកម្មវិធីវិនិយោគសាធារណៈ ការធ្វើថវិកាកម្មសំរាប់កម្មវិធីវិនិយោគសាធារណៈ ការអនុវត្តន៍ និងការតាមដាន និងការអនុវត្តន៍ បណ្តាគំរោងវិនិយោគសាធារណៈ ។

**មាត្រា ២.-** ប្រព័ន្ធជាតិនេះ ត្រូវដំណើរការតាមរយៈគណៈកម្មការគ្រប់គ្រងវិនិយោគ សាធារណៈដែលមានចែងក្នុងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៣១ សសរ.ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ១៩៩៧ ។

## ជំពូកទី១

## ការរៀបចំផែនការ និងកម្មវិធីវិនិយោគ

**មាត្រា ៣.-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និងផែនការក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដោយសហការជាមួយក្រសួងផែនការ ធនាគារជាតិនៃកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់ជាមូលដ្ឋានក្នុងការជ្រើសរើស និងកំណត់លំដាប់អាទិភាពបណ្តាគំរោងការ អភិវឌ្ឍន៍ និងការរៀបចំកម្មវិធីវិនិយោគសាធារណៈរំកិលសំរាប់រយៈពេលបីឆ្នាំ ។

**មាត្រា ៤.-** ក្រសួងផែនការត្រូវណែនាំការរៀបចំកម្មវិធីវិនិយោគសាធារណៈ សំរាប់រយៈពេលមធ្យមដល់គ្រប់បណ្តា ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងមន្ត្រីនិងស្ថាប័នពាក់ព័ន្ធនៅគ្រប់បណ្តាខេត្ត-ក្រុង ។

**មាត្រា ៥.-** ផ្អែកតាមខ្លឹមសារនៃការណែនាំដូចមានចែងក្នុងមាត្រា៤ ខាងលើនេះ បណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំគោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យម ព្រមទាំងបញ្ជីគំរោង និងកម្មវិធីវិនិយោគសាធារណៈ ដើម្បីសំរេចទិសដៅទាំងឡាយដែលមានចែងក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ៥ឆ្នាំ ហើយផ្ញើឯកសារទាំងនេះ មកក្រសួងផែនការ ។

**មាត្រា ៦.-** ក្រសួងផែនការពិគ្រោះពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាពបញ្ចូលគំរោង ទៅក្នុងកម្មវិធីវិនិយោគសាធារណៈរំកិលរយៈពេលមធ្យម ។ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈគណៈកម្មការគ្រប់គ្រង កម្មវិធីវិនិយោគសាធារណៈ ត្រូវពិគ្រោះជាមួយស្ថាប័នជំនាញ ដើម្បីកំណត់លំដាប់ថ្នាក់ និង អាទិភាពនៃកម្មវិធី និងគំរោងដោយបញ្ជាក់ច្បាស់អំពីប្រភេទគំរោងដែលកំពុងអនុវត្ត គំរោងដែល បានសន្យាផ្តល់ជំនួយរួចហើយ គំរោងដែលត្រូវតៀងគរជំនួយបន្ថែមនិងគំរោងដែល ត្រូវការទុនបដិភាគរបស់រាជរដ្ឋាភិបាល ។ ល។

**មាត្រា ៧.-** ផ្អែកតាមលទ្ធផលនៃការពិភាក្សានេះ ក្រសួងផែនការត្រូវរៀបចំកម្មវិធី វិនិយោគសាធារណៈរំកិល ៣ឆ្នាំ ដើម្បីស្នើសុំការសំរេចពីគណៈរដ្ឋមន្ត្រី ។ ក្រសួងផែនការត្រូវផ្ញើបញ្ជីសង្ខេបមួយ ស្តីពីបណ្តាគំរោង អាទិភាពខ្ពស់នៃកម្មវិធីវិនិយោគសាធារណៈ នៃឆ្នាំសារពើពន្ធហើយផ្ញើទៅ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើថវិកាកម្ម ។ កម្មវិធីវិនិយោគសាធារណៈត្រូវរៀបចំឲ្យស៊ីសង្វាក់គ្នា ទៅនឹងដំណើរការនៃការរៀបចំថវិកា ។

**មាត្រា ៨.-** ផ្អែកតាមកម្មវិធីវិនិយោគសាធារណៈរំកិល ៣ឆ្នាំ ផ្អែកលើលទ្ធភាពថវិការបស់រដ្ឋ និង នយោបាយសហប្រតិបត្តិការអភិវឌ្ឍន៍របស់អ្នកផ្តល់ជំនួយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំ បញ្ជីគំរោងវិនិយោគសាធារណៈអាទិភាពសំរាប់តៀងគរជំនួយក្នុងកិច្ចប្រជុំអន្តរជាតិនានា ស្តីពីការស្តារប្រទេសកម្ពុជាឡើងវិញ ដូចជាកិច្ចប្រជុំពិគ្រោះយោបល់ជាដើម ។

## ជំពូកទី ២

## ការរៀបចំថវិកា

**មាត្រា ៩ .-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើថវិកាកម្មសំរាប់កម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំសារពើពន្ធ ក្នុងនោះ មានថវិកាបដិភាគ ដែលជាវិភាគទានរបស់រាជរដ្ឋាភិបាល ក្នុងគំរោងវិនិយោគ សាធារណៈ ដែលហិរញ្ញប្បទានដោយបរទេស ។ ការស្នើមូនសំរាប់អនុវត្តគំរោង ដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ ត្រូវកំណត់ក្នុងសារាចរដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៣

## ការអនុវត្តន៍គំរោងការ

**មាត្រា ១០.-** ក្រសួងស្ថាប័នជំនាញអនុវត្តគំរោង ជាអ្នកទទួលខុសត្រូវចំពោះមុខរដ្ឋ និង ប្រទេស-ស្ថាប័ន ផ្តល់ជំនួយក្នុងការអនុវត្តន៍គំរោង ដោយគោរពឲ្យបានត្រឹមត្រូវនូវច្បាប់ថវិកា និងច្បាប់ហិរញ្ញវត្ថុរបស់រដ្ឋ និងទំរង់បែបបទរបស់អ្នកផ្តល់ជំនួយ ។

## ជំពូក ទី ៤

## ការតាមដានការអនុវត្តន៍គំរោងវិនិយោគសាធារណៈ

**មាត្រា ១១.-** ក្រសួងសេកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវតាមដានការអនុវត្តន៍គំរោងវិនិយោគសាធារណៈ ដែលកំពុងត្រូវបានអនុវត្តដោយស្ថាប័នអនុវត្តន៍គំរោង ។

**មាត្រា ១២.-** ក្រសួងអនុវត្តគំរោងត្រូវរៀបចំរបាយការណ៍ទៀងទាត់ រៀងរាល់ ៦ខែម្តង "ដំណាច់ខែមិថុនា និងខែធ្នូ" ស្តីពីស្ថានភាពនៃការអនុវត្តន៍គំរោង រួមទាំងទិដ្ឋភាពហិរញ្ញវត្ថុ និងបញ្ហាកើតមានឡើងនៅក្នុងពេលអនុវត្តន៍គំរោង មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមគំរូរបាយការណ៍ឯកភាពមួយ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-** ការណែនាំអនុវត្តន៍ អនុក្រឹត្យស្តីពីប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ នឹងត្រូវកំណត់ក្នុងប្រកាសអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ១៤.-** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងផែនការ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធនាគារជាតិនៃកម្ពុជា បណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

***